ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ







# កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយ

## ២០០៩-២០១១



## ស្រុកកៀនស្វាយ ខេត្តកណ្ដាល


រៀបចំដោយ:

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកកៀនស្វាយ

សហការជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្ដាល

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

និង មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី



មិថុនា ២០០៩

# មាតិកា

**អារម្ភកថា** ---------------------------------------------------------- iii

**ក្រុមការងារ**----------------------------------------------------------iv

**១. សេចក្តីផ្តើម**----------------------------------------------------------១

១.១-ប្រវត្តិគ្រោះទឹកជំនន់នៅប្រទេសកម្ពុជា----------------------------------------------------------១

១.២-ការរៀបចំផែនការ និង សារៈសំខាន់ ----------------------------------------------------------៥

ក. ហេតុអ្វីបានជាត្រូវមានផែនការត្រៀមបង្ការគ្រោះទឹកជំនន់? ----------------------------------------------------------៥

ខ. តើចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់អាចជួយយើងបានអ្វីខ្លះ? ----------------------------------------------------------៥

គ. អ្នកណាជាអ្នករៀបចំផែនការៈ ----------------------------------------------------------៥

ឃ. តើផែនការនេះកើតឡើងយ៉ាងដូចម្តេច? ----------------------------------------------------------៦

ង. តើផែនការនេះសម្រាប់អ្នកណា? ----------------------------------------------------------៦

១.៣-ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាព----------------------------------------------------------៧

**២. ទិន្នន័យទូទៅរបស់ស្រុក** ----------------------------------------------------------៧

២.១ ទីតាំងភូមិសាស្ត្រ និង ទំហំផ្ទៃដី ----------------------------------------------------------៧

ក. ភូមិសាស្ត្ររបស់ស្រុក ----------------------------------------------------------៧

ខ. ចំនួនឃុំ ភូមិ និងប្រជាជន----------------------------------------------------------៧

គ. ចំនួនផ្ទៃដី និងសណ្ឋានដី ----------------------------------------------------------៨

២.២ ទិន្នន័យប្រជាសាស្ត្រ----------------------------------------------------------៩

ក. ចំនួនប្រជាពលរដ្ឋ ----------------------------------------------------------៩

ខ. មុខរបរសំខាន់របស់ប្រជាជន---------------------------------------------------------- ១០

គ. ករិតវប្បធមិ ---------------------------------------------------------- ១០

ឃ. សេដ្ឋកិច្ច ---------------------------------------------------------- ១១

២.៣ ប្រវត្តិគ្រោះមហន្តរាយ ---------------------------------------------------------- ១២

ក. ការវិភាគមុខសញ្ញាបង្កគ្រោះថ្នាក់នានាពីឆ្នាំ១៩៩៩-២០០៦ ---------------------------------------------------------- ១២

ខ. ការវិភាគភាពងាយរងគ្រោះ ---------------------------------------------------------- ១២

គ. ផែនទីគ្រោះមហន្តរាយទឹកជំនន់ឆ្នាំ២០០០ របស់ស្រុកកៀនស្វាយ ---------------------------------------------------------- ១៤

២.៤. ធនធានផ្សេងៗ------------------------------------------------------------ ១៥
ក. ទិន្នន័យសាលារៀន និង សិស្ស ( ស្ថិតិសិក្សាឆ្នាំ ២០០៦-២០០៧) ------------------------------ ១៥
ខ. មណ្ឌលសុខភាព និង មន្ទីរពេទ្យ------------------------------------------------ ១៥
គ. ទីទួលសុវត្ថិភាព និង ទីតាំង ---------------------------------------------------- ១៦
ឃ. មធ្យោបាយដឹកជញ្ជូន-------------------------------------------------------- ១៦
ង. ប្រព័ន្ធធារាសាស្ត្រ----------------------------------------------------------- ១៧
ច. ប្រព័ន្ធទំនាក់ទំនង ------------------------------------------------------------ ១៧

**៣. ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ** --------------១៩
៣.១ ក្របខណ្ឌ័ការងារនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ------------------------------១៩
៣.២ តារាងសង្ខេបគម្រោងអាទិភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ----------------------- ២១

**៤. យន្តការស្ថាប័ន និង ការគ្រប់គ្រងគ្រោះមហន្តរាយ** ------------------------------------------ ២៣
៤.១ សមាសភាព ---------------------------------------------------------------- ២៣
៤.២ តួនាទី និង ការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ---------------- ២៣
៤.៣ រចនាសម្ពន្ធ័គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក----------------------------------២៤
៤.៤ ក្រុមប្រតិបត្តិការ ------------------------------------------------------------២៥

**៥.ផែនការសកម្មភាពត្រៀមបង្ការគ្រោះទឹកជំនន់តាមការិយាល័យ-អង្គភាពសំខាន់ៗជុំវិញស្រុក សំរាប់អនុវត្តឆ្នាំះ ២០០៩-២០១១** ------------------------------------------------------------------២៩

**ឧបសម្ពន្ធ័**
១. ដីកា និង សេចក្តីណែនាំ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់គណៈកម្មាធិការ គ្រប់គ្រងគ្រោះមហន្តរាយស្រុក កៀនស្វាយ
២. អង្គការក្រៅរដ្ឋាភិបាលនានាក្នុងស្រុក កៀនស្វាយ
៣.ផែនទីស្រុក កៀនស្វាយ

# **អារម្ភកថា**

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់របស់ស្រុកកៀនស្វាយ ជាផែនការយុទ្ធសាស្ត្រសំរាប់អនុវត្តកម្មវិធីគ្រប់គ្រងគ្រោះទឹកជំនន់ថ្នាក់ស្រុក ដែលមានបីដំណាក់កាលសំខាន់ៗ ដូចជាកម្មវិធីត្រៀមបង្ការមុខពេលគ្រោះទឹកជំនន់ កម្មវិធីឆ្លើយតបក្នុងពេលគ្រោះទឹកជំនន់ និងកម្មវិធីស្តារ និងជួសជុលឡើងវិញក្រោយពេលទឹកជំនន់ ។

ផែនការនេះត្រូវបានការសហការពីគ្រប់បណ្តាវិស័យជំនាញ រៀបចំក្នុងគោលបំណង ឆ្លុះបញ្ចាំងពីបញ្ហាតំរូវការជាអាទិភាពរបស់ស្រុកកៀនស្វាយ សំដៅកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីទឹកជំនន់ទន្លេមេគង្គ ធ្វើអោយភាពរងគ្រោះនៅ ក៏រិតទាបជាអប្បរមា និងជាមូលដ្ឋានពង្រឹងកិច្ចសហប្រតិបត្តិការឆ្លើយតប និង សង្គ្រោះបន្ទាន់ប្រកបដោយប្រសិទ្ធិភាពទាន់ពេលវេលា ព្រមទាំងការស្តារ និង ជួសជុលឡើងវិញក្រោយពេលគ្រោះទឹកជំនន់បានឆាប់រហ័ស ដើម្បីធ្វើអោយជីវភាពសង្គមមានប្រក្រតីភាពឡើងវិញ ឆ្លើយតបទៅនឹង គោលនយោបាយកាត់បន្ថយភាពក្រីក្រ ក្នុងយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំ ។

ក្នុងនាម **អភិបាលស្រុក** និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះកិច្ចឧបត្ថម្ភគាំទ្ររបស់គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ ( NCDM ) មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី ( ADPC ) គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល ដែលបានជួយលើការងារបច្ចេកទេស ។ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ( CNMC ) គណៈកម្មាធិការទន្លេមេគង្គ ( MRC ) ផ្តល់ការងារសំរបសំរួល និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសប្រទេសអាឡឺម៉ង់ ( GTZ ) ដែលបានជួយផ្តល់ជំនួយថវិកាដល់ការកសាងគំរោងផែនការនេះ ។ ព្រមជាមួយនេះសូមថ្លែងអំណរគុណដល់បណ្តាការិយាល័យអង្គភាពជុំវិញស្រុក ក្រុមប្រឹក្សាឃុំដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកកៀនស្វាយ និងបណ្តាអង្គការជាតិ អន្តរជាតិ ដែលបានខិតខំប្រឹងប្រែងចូលរួមផ្តល់យោបល់ប្រកបដោយបញ្ញាញាណ និង បទពិសោធន៍ជួយកែលំអផែនការនេះ ក្នុងអង្គសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ស្រុកធ្វើអោយស្រុកកៀនស្វាយ សំរេចបានការរៀបចំនូវផែនការ ជាយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ ។

ជាទីបញ្ចប់ ខ្ញុំសូមអំពាវនាវ ដល់បណ្តាមន្ទីរជំនាញ អង្គការជាតិ អង្គការអន្តជាតិ អង្គការមនុស្សធម៌នានា សប្បុរសជនក្នុង និង ក្រៅប្រទេស មេត្តាបន្តជួយឧបត្ថម្ភផ្តល់នូវធនធានជាស្មារតី សំភារៈថវិកាដល់គំរោងដំណោះស្រាយ បញ្ហាជាអាទិភាពកាត់បន្ថយគ្រោះមហន្តរាយដែលកើតមាននៅក្នុងស្រុកយើងខ្ញុំ ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា និងបានទទួលការឆ្លើយតបទាន់ពេលវេលា ដើម្បីរួមចំណែកកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ក៏ដូចជាការកាត់បន្ថយភាពក្រីក្រ នាំមកនូវវឌ្ឍនៈភាពសំរាប់ប្រជាពលរដ្ឋយើង ។

ធ្វើនៅកៀនស្វាយ.ថ្ងៃទី..១៩..ខែ..មិថុនា....ឆ្នាំ ២០០៩

**អភិបាលស្រុកនិងជាប្រធានគណៈកម្មាធិការ**
**គ្រប់គ្រងគ្រោះមហន្តរាយស្រុក**

ហេង_ឡៀម

# ក្រុមការងារ

កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយស្រុកកៀនស្វាយ ខេត្តកណ្តាល ត្រូវបានកែសម្រួលនឹងធ្វើបច្ចុប្បន្នភាព ដោយ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកក្រោមកិច្ចគាំទ្របច្ចេកទេសពី គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត(PCDM) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM) និង មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី( ADPC) ដូចមានសមាសភាពខាងក្រោម :

- **សមាសភាពក្រុមការងារ:**

១ . លោក សុទ្ធ គីមកុលមុនី មន្ត្រីលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២. លោក លឹម គីមនី អគ្គលេខាធិការរងសាលាខេត្តកណ្តាល និងជាមន្ត្រីលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត

៣. លោក អ៊ូ ឈាង អភិបាលរងស្រុកកៀនស្វាយ ទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយស្រុក

៤. លោក អុល សែន មន្ត្រីសម្របសម្រួលកម្មវិធី នៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

៥.លោក ព្រៃ ស៊ីណាំង មន្ត្រីលេខាធិការដ្ឋានស្រុកកៀនស្វាយ

- **ពិនិត្យតាមដាន និងផ្តល់បច្ចេកទេស:**

១. ឯ.ឧ. ប៉ុន ណារិទ្ធិ អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២. ឯ.ឧ អ៊ូ សំអួន អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល

៣.លោក ហេង ធៀម អភិបាលស្រុកកៀនស្វាយ

៤. លោក ជុំ វុទ្ធី ប្រធានគម្រោងថ្នាក់ជាតិ នៃមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

**ស្ថាប័នដែលបានចូលរួមចំណែក:**

- ការិយាល័យ និង អង្គភាព ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកកៀនស្វាយ
- តំណាងអង្គការជាតិ-អន្តរជាតិ ក្នុងស្រុកកៀនស្វាយ

# កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយ

# ស្រុកកៀនស្វាយ

## ១. សេចក្តីផ្តើម

### ១.១-ប្រវត្តិគ្រោះទឹកជំនន់នៅប្រទេសកម្ពុជា

ទន្លេមេគង្គ ជាអាយុជីវិតរបស់ប្រជាជនកម្ពុជា ។ ទន្លេមេគង្គ និង ដៃរបស់វា និង ផ្តល់ទឹកភ្លៀងដ៏ច្រើនលើសលប់ ជាហេតុធ្វើឱ្យមានទឹកជំនន់ប្រចាំឆ្នាំ ប៉ះពាល់មកលើតំបន់ដែលមានផ្ទៃក្រលា ប្រហែល ១២ គីឡូម៉ែត្រក្រឡា ឬ ស្មើនឹង ៣១ ភាគរយនៃផ្ទៃដីទំនាបនៃអាងទន្លេមេគង្គ។ ភ្លៀងធ្លាក់ខ្លាំង នៅរដូវវស្សា និងការកាប់បំផ្លាញព្រៃឈើ បានធ្វើឱ្យមានទឹកជំនន់លឿន។ ជាញឹកញាប់លំហូរទឹកទន្លេមេគង្គមានភាពខ្ពស់ជាងច្រាំងទន្លេ ដោយសារតែមានភ្លៀងធ្លាក់ខ្លាំង មានទឹកហូរមកចាក់ក្នុងអាងទន្លេបានធ្វើឱ្យមានទឹកជំនន់ នៅតាមបណ្តាខេត្តដែលមានទីតាំងនៅតាមតំបន់ទំនាប។ តំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់ នៅជុំវិញស្រុកកៀនស្វាយ មានផ្ទៃដីប្រមាណ៣៦.៥គីឡូម៉ែត្រក្រលា ។ ឃុំដែលប្រឈមមុខនឹងគ្រោះទឹកជំនន់ទន្លេមេគង្គ រួមមាន: ឃុំក្បាលកោះ , ភូមិធំ, គគីរ, ដីឥដ្ឋ, បន្ទាយដែក, សំរោងធំ និង ឃុំគគីរធំ ។

ទឹកជំនន់នៅឆ្នាំ ២០០០ ត្រូវបានគេរាយការណ៍ថា មានសភាពធ្ងន់ធ្ងរជាងគេ នៅក្នុងរយះពេលជាង០៣ឆ្នាំ ។ តាមរបាយការណ៍បានឱ្យដឹងថា មានមនុស្សស្លាប់ចំនួន ៩នាក់ ( ក្នុងនោះ ៧០% ជាកុមារ ) ប្រជាជនចំនួន ១.២៤០គ្រួសារស្មើរនឹងចំនួនមនុស្ស ៦២៣៤ នាក់ នៅក្នុងឃុំ បានទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយ ទឹកជំនន់ ក្នុងនោះប្រជាជនចំនួន ៧១៤ គ្រួសារស្មើនឹង មនុស្សចំនួន ៣៥៧៣ នាក់ បានជម្លៀសទៅស្នាក់នៅទីទួលសុវត្ថិភាព។ លើសពីនេះទៀតផ្ទះចំនួន ៣៤៨ខ្នង ទទួលរងការប៉ះពាល់ក្នុងនោះ ២៣៥ ខ្នងត្រូវខូចខាតទាំងស្រុង។ ដំណាំកសិកម្ម និងដំណាំផ្សេងៗទៀតចំនួន ៣៥៤ហិចតា ត្រូវទទួលរងការប៉ះពាល់ និង ខូចខាត។ ផ្អែកតាមរបាយការណ៍របស់មូលដ្ឋាន ប៉ាន់ស្មាន និងវាយតម្លៃផលប៉ះពាល់ និងការខូចខាតសរុបអស់ប្រហែល ៣០ម៉ឺនដុល្លារអាមេរិក។

*ស្ថិតិ និង ទិន្នន័យសង្ខេប ពីផលប៉ះពាល់ទឹកជំនន់ឆ្នាំ ២០០០-២០០១-២០០២:*

- ផ្នែកអប់រំ សិក្សាធិការ : សាលារៀនទទួលការខូចខាតចំនួន ១៥ខ្នង
- ផ្នែកសុខភាព : មណ្ឌលសុខភាពខូចខាតចំនួន ០២ខ្នង
- ផ្នែកកសិកម្ម :-ស្រូវទទួលរងការខូចខាតប្រវែង ៥៧៥ហិចតា
- ដំណាំផ្សេងទទួលរងការខូចខាតចំនួន ៤៣០ហិចតា
- អណ្តូងទឹក និង លូទឹក ៥៧កន្លែង
- ប្រព័ន្ធធារាសាស្រ្ត ២៤កន្លែង

គេទទួលស្គាល់ថា នៅក្នុងអាងទន្លេមេគង្គ ទឹកជំនន់បានកើនឡើងផ្ទួនៗ បានធ្វើឱ្យសំបូរត្រី និង ជីវៈចម្រុះ នៅក្នុងតំបន់ អាចផ្តល់ទឹក ផ្លូវនាវាចរ និង ធ្វើឱ្យដីកសិកម្មមានជីវជាតិ។ ទាក់ទងទៅនឹង តំបន់ ដីសើមនៅតាមទំនាប ជាប្រភពសម្រាប់ជីវភាពរស់នៅរបស់ប្រជាជន រាប់ពាន់គ្រួលសារ សម្រាប់ ប្រកបរបរ ចិញ្ចឹមជីវិតនៅតាមតំបន់ដីសើម នេះ។

ទន្ទឹមគ្នានេះ ទឹកជំនន់ទន្លេមេគង្គបានបង្ករឱ្យមានការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ និង រំខាន ដល់សកម្មភាពអភិវឌ្ឍន៍សង្គម និង ការបង្កបង្កើនផលរបស់ប្រជាជននៅតាមតំបន់អាងទន្លេមេគង្គនេះផងដែរ។ ដូច្នេះសកម្មភាព និង វិធានការកាត់បន្ថយ ផលប៉ះពាល់គ្រោះទឹកជំនន់ត្រូវបានរៀបចំធ្វើ ដូចជាការអន្តរាគមន៍ ជាក់ស្តែងរៀបចំគោលនយោបាយ និង ការរៀបចំផែនការ ដើម្បីទាញយកផលប្រយោជន៍ពីទឹកជំនន់ ដើម្បីធានាកាអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពនៅក្នុងប្រទេស ។ដូចគ្នានេះដែរដើម្បី កាត់បន្ថយផលប៉ះពាល់លើអាយុជីវិត និង ទ្រព្យសម្បត្តិរបស់ប្រជាជន ។ សកម្មភាព និងវិធានការណ៍ដែលបានធ្វើកន្លង មកទាក់ទងនឹងការគ្រប់គ្រងគ្រោះទឹកជំនន់ គឺផ្តោតសំខាន់តែលើការងារប្រតិបត្តិការជំនួយសង្គ្រោះបន្ទាន់ តែការងារត្រៀមបង្ការ និង កាត់បន្ថយ គ្រោះទឹកជំនន់ជាការងារចាំបាច់ត្រូវធ្វើនិងយកចិត្តទុកដាក់បំផុតដូចពាក្យចាស់លោកថា"ការពារប្រសើរជាងព្យាបាល" ពេលណាដែលទឹកជំនន់បាននាំមកនូវផលប្រយោជន៍ជូនប្រជាជន។តាមបទពិសោធពីអតីតកាលបានបង្ហាញឱ្យយើងដឹងថា ការចូល រួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ និង ការចូលរួមជាភាគទានជាធនធានដែលអាចមាន ដើម្បីធ្វើឱ្យការអនុវត្តន៍កម្មវិធី ត្រៀមបង្ការគ្រោះទឹកជំនន់នៅតាមមូលដ្ឋាន វាអាចជួយឱ្យប្រជាជននៅតាមមូលដ្ឋានវាអាចជួយឱ្យប្រជាជនអាចដោះស្រាយបាន យ៉ាងមានប្រសិទ្ធភាព និង ទាន់ពេលវេលាទៅនឹង គ្រោះទឹកជំនន់តាមរយៈវិធានការនានា។

ស្រុកកៀនស្វាយស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គ ទន្លេបាសាក់ និងមានព្រែកជាច្រើនហូរឆ្លងកាត់ជាតំបន់ទំនាបដែលងាយនឹងទទួលរងគ្រោះខ្លាំង ពីទឹកជំនន់ទន្លេមេគង្គ និងទន្លេបាសាក់ ។ ដោយសារស្រុកមានទីតាំងភូមិសាស្ត្របែបនេះ ទើបទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយទឹកទន្លេមេគង្គ និងទន្លេបាសាក់ ជាប់ៗគ្នា ឆ្នាំ ២០០០-២០០១-២០០២។

តាមរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក បានឱ្យដឹងថា តាមបណ្តាឆ្នាំខាងលើទឹកជំនន់ទន្លេមេគង្គ និង ទន្លេបាសាក់បានបង្ករការប៉ះពាល់ និងការខូចខាតលើវិស័យ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និង បង្ករឱ្យមនុស្ស និង សត្វស្លាប់ច្រើន ដូចមាននៅក្នុងរបាយការណ៍សង្ខេប ដូចឱ្យខាងក្រោម :

*** ផលប៉ះពាល់ឆ្នាំ ២០០០**

| | |
|---|---|
| - មនុស្សស្លាប់ | ៥នាក់ |
| - ប្រជាជនដែលទទួលរងការប៉ះពាល់ | ៨៣៥គ្រួសារ ស្មើនឹង ៤.២១៥នាក់ |
| - ចំនួនឃុំដែលទទួលរងគ្រោះ | ០៧ ឃុំ ស្មើនឹង ២៦ភូមិ |
| - ចំនួនផ្ទះបាក់រលំ | ១៣១ខ្នង |

| | |
|---|---|
| - ផ្ទះលិចទឹកពុំអាចស្នាក់នៅបាន | ២៨៥ខ្នង |
| - ផ្ទះទល់ទ្រលើកធ្វើស្នាក់នៅបណ្តោះអាសន្ន | ១៨២ខ្នង |
| - ស្ពានថ្មបាក់ | ៤កន្លែង |
| - ស្ពានថ្មទទួលរងការខូចខាត | ៧កន្លែង |
| - អាងទឹកដែលទទួលរងការខូចខាត | ៦ កន្លែង គិតជាសាច់ដី ១៦.០០០ម៉ែត្រគីប |
| - ផ្លូវលំខូចខាតអស់សាច់ដីចំនួន | ៣៧.០០០ម៉ែត្រគីប |
| - ទំនប់អាងទឹកទទួលរងការខូចខាត | ១៨ កន្លែង គិតជាសាច់ដី ៣៥.០០០ម៉ែត្រគីប |
| - ប្រឡាយទទួលរងការខូចខាត | ៣.៨០០ម៉ែត្រ |
| - លូខូចខាត | ២៧ កន្លែង |
| - ស្រូវវស្សាខូចខាត | ២៤៥ ហិចតា |
| - ដំណាំអនុសាសន៍ និង បន្លែខូចខាតអស់ | ១៨៧ ហិចតា |
| - សត្វពាហនៈងាប់ | ១.៣២២ ក្បាល |
| - សាលារៀនទទួលការប៉ះពាល់ | កន្លែង |
| - វត្តលិចទឹក | ១៥ វត្ត |
| - អណ្តូងទឹកខូចខាត | ៣១ កន្លែង |
| - សាលាដែលរងការប៉ះពាល់ | ០៨ ខ្នង ស្មើនឹង ៤៨ បន្ទប់ |

## * ផលប៉ះពាល់ឆ្នាំ ២០០១

| | |
|---|---|
| - មនុស្សស្លាប់ | ២ នាក់ |
| - ប្រជាជនដែលទទួលរងការប៉ះពាល់ | ២១៦ គ្រួសារ ស្មើនឹង ១.១៥០ នាក់ |
| - ចំនួនឃុំទទួលរងគ្រោះ | ៥ ឃុំ ស្មើនឹង ១៤ ភូមិ |
| - ផ្ទះខូចខាតទាំងស្រុងចំនួន | ៤១ ខ្នង |
| - ផ្ទះលិចទឹកពុំអាចស្នាក់នៅបាន | ៥៣ ខ្នង |
| - ផ្ទះទល់ទ្រស្នាក់នៅបណ្តោះអាសន្ន | ៣៥ ខ្នង |
| - ផ្ទះរុះរើដោយបាក់ច្រាំងទន្លេ | ៧៥ ខ្នង |
| - ស្ពានថ្មទទួលរងការខូចខាត | ២ កន្លែង |
| - ផ្លូវលំខូចខាតអស់ចំនួន | ១.៨០០ ម៉ែត្រ |

| | |
|---|---|
| - ស្រូវវស្សាខូចខាតអស់ | ៨៧ ហិចតា |
| - ដំណាំអនុសាសន៍ និង បន្លែខូចខាតអស់ | ៩៥ ហិចតា |
| - ដំណាំអនុផលខូចខាតអស់ | ៤៨ ហិចតា |
| - សត្វពាហនៈងាប់ | ៣១៨ ក្បាល |
| - សាលារៀនទទួលការប៉ះពាល់ | ០១ ខ្នង ស្មើនឹង ០៥ បន្ទប់ |
| - អណ្តូងទឹកខូចខាត | ២៦ កន្លែង |

*** ផលប៉ះពាល់ឆ្នាំ ២០០២**

| | |
|---|---|
| - មនុស្សស្លាប់ | ២ នាក់ |
| - ប្រជាជនដែលទទួលរងការប៉ះពាល់ | ៧៤ គ្រួសារ ស្មើនឹង ៣១០ នាក់ |
| - ចំនួនឃុំទទួលរងគ្រោះ | ៣ ឃុំ ស្មើនឹង ៨ ភូមិ |
| - ផ្ទះខូចខាតទាំងស្រុងចំនួន | ៧ ខ្នង |
| - ផ្ទះលិចទឹកពុំអាចស្នាក់នៅបាន | ៤៥ ខ្នង |
| - ផ្ទះទល់ទ្រស្នាក់នៅបណ្តោះអាសន្ន | ៧ ខ្នង |
| - ផ្ទះរុះរើដោយបាក់ច្រាំងទន្លេ | ១២ ខ្នង |
| - ស្ពានថ្មទទួលរងការខូចខាត | ២ កន្លែង |
| - ផ្លូវលំខូចខាតអស់ចំនួន | ៤២០ ម៉ែត្រ |
| - ទំនប់អាងទឹកទទួលរងការខូចខាត | ១.២០០ ម៉ែត្រ |
| - ប្រឡាយខូចខាត | ១.៣០០ ម៉ែត្រ |
| - សត្វពាហនៈងាប់ | ៨៧ ក្បាល |
| - ស្រូវវស្សាខូចខាតអស់ | ១៤៣ ហិចតា |
| - ដំណាំអនុផលខូចខាតអស់ | ២៥ ហិចតា |

*** ផលប៉ះពាល់ឆ្នាំ ២០០៣-២០០៧**

| | |
|---|---|
| - ផ្ទះរលំដោយខ្យល់ព្យុះ | ៧៨ ខ្នង |
| - ខូចខាតដំណាំអនុផល | ១៥៤ ហិចតា |

- សាលារៀនទទួលការប៉ះពាល់ ០៦ ខ្នង ស្មើនឹង ៣១ បន្ទប់

## ១.២. ការរៀបចំផែនការ និង សារៈសំខាន់

### ក. ហេតុអ្វីបានជាត្រូវមានផែនការត្រៀមបង្ការគ្រោះទឹកជំនន់?

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ជាវិធានការ ឬសកម្មភាព សម្រាប់អនុវត្តជាមុន ដើម្បីធ្វើឱ្យការឆ្លើយតប និង ស្តារឡើងវិញ ពីផលប៉ះពាល់ដោយគ្រោះទឹកជំនន់បានទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ផែនការត្រៀមបង្ការគ្រោះ ទឹកជំនន់មានទិសដៅ និង តួនាទីសំខាន់ៗ ២ ដូចខាងក្រោម :

- វាយតម្លៃធនធាន និង សមត្ថភាពដែលមានស្រាប់នៅគ្រប់ថ្នាក់ រួមមាន ថ្នាក់ស្រុក ឃុំនិង ភូមិ។
- រៀបចំនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ការងារត្រៀមបង្ការ ប្រតិបត្តិការឆ្លើយតបសង្គ្រោះ និងស្តារឡើងវិញ ទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះទឹកជំនន់ ឧទាហរណ៍ ដូចជា ការផ្តល់ព័ត៌មានជាមុនពីគ្រោះថ្នាក់ដែលអាចកើតឡើងឱ្យទាន់ពេលវេលា ការជម្លៀសប្រជាជន និងទ្រព្យសម្បត្តិជាមុនពីកន្លែង គ្រោះថ្នាក់ រៀបចំជម្រកបណ្តោះអាសន្ន ការស្តុកទុកជំនួយសង្គ្រោះ និង ការរៀបចំប្រព័ន្ធទំនាក់ទំនង សម្រាប់ប្រើប្រាស់នៅក្នុងដំណាក់កាលៈ មុនពេល ក្នុងពេល និង ក្រោយពេលគ្រោះមហន្តរាយកើតឡើង។

### ខ. តើផែនការត្រៀមបង្ការគ្រោះទឹកជំនន់អាចជួយយើងបានអ្វីខ្លះ?

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ អាចជួយឱ្យមានការរៀបចំ និងកំណត់ធនធានសម្រាប់ប្រើប្រាស់ក្នុងការកាត់បន្ថយផលប៉ះពាល់គ្រោះមហន្តរាយ។ ការរៀបចំផែនការបានល្អអាចជួយយើងនៅក្នុងការងារមួយចំនួនដូចខាងក្រោមៈ

- សហគមន៍ងាយរងគ្រោះអាចទទួលបានព័ត៌មានបានទាន់ពេលវេលាដូចជា ព័ត៌មានព្យាករណ៍ និង ព័ត៌មាន ប្រកាសភាពអាសន្នជាដើម
- អាចផ្តល់ឱ្យនូវសេចក្តីត្រូវការចាំបាច់ ដូចជា ជម្រកបណ្តោះអាសន្ន ការថែទាំសុខភាព ទឹកស្អាត និងម្ហូបអាហារ ជូនជនរងគ្រោះ នៅរដូវទឹកជំនន់
- អាចកាត់បន្ថយផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាជន
- អាចស្តារឡើងវិញបានទាន់ពេលវេលា នូវផលប៉ះពាល់លើហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើឱ្យកិច្ចសហការបានល្អ និងមានប្រសិទ្ធភាពក្នុងចំណោមអង្គការ និងស្ថាប័នពាក់ព័ន្ធ ក្នុងការឆ្លើយតបនៅពេលមានគ្រោះទឹកជំនន់
- អាចធ្វើឱ្យសហគមន៍វិលប្រឡប់ទៅរកស្ថានភាពដើមវិញបានយ៉ាងឆាប់រហ័ស

### គ. អ្នកណាជាអ្នករៀបចំផែនការៈ

ផែនការនេះរៀបចំឡើងដោយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ការិយាល័យ និង អង្គភាពជាសមាជិករបស់ខ្លួនជុំវិញស្រុក ក្រោមការគាំទ្របច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី គណៈកម្មាធិការ ជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

ផែនការនេះ ជាផែនការមេ សម្រាប់អនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក ដែលអាចធានាធ្វើឱ្យមានការ ត្រៀមបង្ការ ការឆ្លើយតប និងស្តារឡើងវិញ បានទាន់ពេលវេលា និងមានប្រសិទ្ធភាព និងសំដៅកាត់បន្ថយនូវផលប៉ះពាល់ និងខូចខាតលើអាយុជីវិតមនុស្ស-សត្វ ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ និង សេដ្ឋកិច្ចសង្គម ដែលបង្កឡើងដោយគ្រោះ មហន្តរាយធម្មជាតិ ជាពិសេសគ្រោះមហន្តរាយទឹកជំនន់ ។

## ឃ. តើផែនការនេះកើតឡើងយ៉ាងដូចម្តេច?

ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី(ADPC) និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និង អ្នកជំនាញការជាតិ និងអន្តរជាតិដែលមានបទពិសោធទាក់ទងនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកបានរៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាពលើផែនការត្រៀមបង្ការគ្រោះទឹកជំនន់របស់ខ្លួន ដែលបានរៀបចំ ឡើងតាំងពីឆ្នាំ២០០៧ ឱ្យកាន់តែមានលក្ខណៈស៊ីជំរៅ និងគ្រប់ជ្រុងជ្រោយជាងមុន តាមរយៈការកែសំរួលលើផែនការ មានលក្ខណៈរួម ទៅជាផែនការសកម្មភាពដែលមានលក្ខណៈដោយឡែកតាមកម្មវិធីស្នូលរបស់ការិយាល័យ អង្គភាពនីមួយៗ ជុំវិញស្រុក និង បានអនុម័តជាផ្លូវការនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ស្រុក ។

## ង. តើផែនការនេះសម្រាប់អ្នកណា?

ក្រោយពីបានរៀបចំបានពេញលេញ និងទទួលបានការយល់ព្រមឱ្យប្រើប្រាស់ ពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ឯកសារផែនការនេះនឹងធ្វើការបែងចែក និងផ្សព្វផ្សាយទៅដល់ការិយាល័យ អង្គភាពដែលជាសមាជិកគណៈ កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយសុក ដើម្បីចាប់ផ្តើមអនុវត្តទៅតាមតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដូចបាន កំណត់នៅក្នុងផែនការ ដើម្បីធ្វើឱ្យសម្រេចបានទៅតាមទិសដៅ និងលទ្ធផល ដូចបានកំណត់នៅក្នុងវិធានការ និងសកម្មភាព នីមួយៗ។ ឯកសារផែនការនេះ នឹងដាក់ជូនគណៈកម្មាធិការគ្រប់គ្រង គ្រោះមហន្តរាយខេត្ត ដើម្បីបញ្ចូលផែនការនេះទៅក្នុង ផែនការរបស់ គណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយ និងធ្វើការផ្សព្វផ្សាយផងដែរដល់រាជរដ្ឋាភិបាលជាតិ ជាពិសេស គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីបញ្ចូលផែនការនេះទៅក្នុងផែនការឆ្នាំនៃកម្មវិធីអភិវឌ្ឍន៍ជាតិ ខេត្ត ស្រុក និង ឃុំ។ លើសពីនេះទៀត ឯកសារផែនការនេះ នឹង ធ្វើការផ្សព្វផ្សាយ ដល់បណ្តា អង្គការជាតិ-អន្តរជាតិពាក់ព័ន្ធ ទាំងនៅក្នុង និងក្រៅស្រុក ដើម្បីបានទទួលនូវការចូលរួមគាំទ្រទាំងផ្នែកថវិកា និងបច្ចេកទេស សម្រាប់ធានាធ្វើឱ្យផែន ការអាចសម្រេចបានលទ្ធផលល្អ និងគោលដៅ ដូចមានចែងក្នុងផែនការនេះ ។

## ១.៣-ការកែសម្រួល និងការធ្វើបច្ចុប្បន្នភាព

ក. ស្ថាប័នអនុវត្តផែនការ: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកកៀនស្វាយ

ខ. ផែនការសម្រាប់ឆ្នាំ : ២០០៩-២០១១

គ. ស្ថាប័នទទួលខុសត្រូវលើការកែសម្រួល
និង ធ្វើបច្ចុប្បន្នភាពផែនការ: គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ក្រោមជំនួយបច្ចេកទេសពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី

ឃ. កាលបរិច្ឆេទកែសម្រួលផែនការ: ខែធ្នូ ឆ្នាំ២០១១

# ២. ទិន្នន័យទូទៅរបស់ស្រុក

## ២.១ ទីតាំងភូមិសាស្ត្រ និង ទំហំផ្ទៃដី

### ក. ភូមិសាស្ត្ររបស់ស្រុក

ស្រុកកៀនស្វាយ មានទីតាំងស្ថិតនៅខាងកើតរាជធានីភ្នំពេញ ចំងាយ ១៥ គីឡូម៉ែត្រ លាតសន្ធឹងតាមបណ្តោយផ្លូវជាតិលេខ ១ អមដោយទន្លេធំពីរគឺ ទន្លេមេគង្គ និង ទន្លេបាសាក់ ដែលមានព្រំប្រទល់:

- ខាងលិច ជាប់ខ័ណ្ឌមានជ័យរាជធានីភ្នំពេញ
- ខាងកើត ទល់នឹងស្រុកលើកដែក
- ខាងជើង ទល់នឹងទន្លេមេគង្គ និង ស្រុកល្វាឯម
- ខាងត្បូង ទល់នឹងទន្លេបាសាក់ ស្រុកតាខ្មៅ និង ស្រុកស្អាង ។

ស្រុកកៀនស្វាយចែកចេញជា 12 ឃុំ ក្នុងនោះដែរចំនួន 09 ឃុំ ស្ថិតតាមបណ្តោយផ្លូវជាតិលេខ 1 អមដោយទន្លេមេគង្គប្រវែង 43 គ.ម ហើយចំនួន 03 ឃុំទៀតគឺឃុំកំពង់ស្វាយ, ព្រែកថ្មី និង ឃុំឈើទាល ស្ថិតតាមដងទន្លេបាសាក់មានប្រវែង 19 គ.ម ។ ឃុំដែលជាទីប្រជុំជនមាន 03ឃុំគឺ ព្រែកឯង, វាលស្បូវ និងឃុំគគីរ ។ ទីតាំងសាលាស្រុកស្ថិតនៅឃុំគគីរ ចំងាយ 15 គ.ម ពីរាជធានីភ្នំពេញ ។

### ខ. ចំនួនឃុំ ភូមិ និងប្រជាជន

| ល.រ | ឈ្មោះឃុំ | ចំនួនភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាជន គិតជានាក់ |
|---|---|---|---|---|
| 1 | បន្ទាយដែក | 03 | 2.649 | 12.896 |
| 2 | ឈើទាល | 04 | 1.831 | 9.911 |

| | | | | |
|---|---|---|---|---|
| 3 | ដីឥដ្ឋ | 03 | 2.925 | 14.441 |
| 4 | កំពង់ស្វាយ | 03 | 1.888 | 9.562 |
| 5 | ក្បាលកោះ | 03 | 2.963 | 15.364 |
| 6 | គគីរ | 04 | 3.251 | 15.716 |
| 7 | គគីរធំ | 04 | 2.514 | 15.148 |
| 8 | ភូមិធំ | 03 | 2.106 | 11.129 |
| 9 | ព្រែកឯង | 06 | 2.700 | 13.296 |
| 10 | ព្រែកថ្មី | 03 | 2.740 | 17.050 |
| 11 | សំរោងធំ | 06 | 4.206 | 19.769 |
| 12 | វាលស្បូវ | 04 | 1.512 | 7.336 |
| ***សរុប*** | | ***46*** | ***31.285*** | ***161.618*** |

### គ. ចំនួនផ្ទៃដី និងសណ្ឋានដី

ស្រុកកៀនស្វាយ មានផ្ទៃដីសរុប **38.211** ហិចតា ហើយចែកចេញជាៈ ដីតំបន់ទំនាប ជាផ្ទៃដីសម្រាប់បង្កបង្កើនផលដំណាំដែលមានដំណាំស្រូវ **6.341** ហិចតា ក្នុងនោះមានដីស្រែប្រាំងចំនួន **5.461** ហិចតា, ស្រែវស្សា **880** ហិចតា និងផ្ទៃដីដាំដំណាំអនុផលមាន **4.031** ហិចតា និង ដីសំបូរវាលស្មៅ ។

ដីលំនៅដ្ឋាន និង សំណង់ផ្សេងៗ មាន **6.235,02** ហិចតា

ដីព្រែក បឹងបួរ ទន្លេ មាន **5.281,97** ហិចតា និង ដីព្រៃឈើ **10.397,9** ហិចតា ។

| **ល.រ** | **ឈ្មោះឃុំ** | **ដីស្រែ** | | | | | | **ផ្សេងៗ** |
|---|---|---|---|---|---|---|---|---|
| | | **ស្រែវស្សា** | | | **ស្រែប្រាំង** | | | |
| | | **ផ្ទៃដីសរុប ហ.ត** | **ពឹងលើទឹកភ្លៀង ហ.ត** | **បញ្ចូលទឹកបង្ហូប់ ហ.ត** | **ផ្ទៃដីសរុប ហ.ត** | **បញ្ចូលទឹកទាំងស្រុង ហ.ត** | **បញ្ចូលទឹកបង្ហូប់ ហ.ត** | |
| ១ | បន្ទាយដែក | ១៥០ | ១៥០ | ០០ | ១១៥០ | ៦៥២ | ៤៩៨ | **ប្រភេទស្រូវស្រាល** |
| ២ | ឈើទាល | ១៥០ | ១៥០ | ០០ | ៣៧៨ | ៣១៥ | ៦៣ | |
| ៣ | ដីឥដ្ឋ | ៤២ | ៤២ | ០០ | ៥៦៧ | ៤០៧ | ១៦០ | |
| ៤ | កំពង់ស្វាយ | ១២៥ | ១២៥ | ០០ | ៥៧៧ | ៣៩៧ | ១៨០ | |
| ៥ | ក្បាលកោះ | ៥៥ | ៥៥ | ០០ | ២៨០ | ២២៨ | ៥២ | |
| ៦ | គគីរ | ៣៩ | ៣៩ | ០០ | ១៨៥ | ១៣៩ | ៤៦ | |
| ៧ | គគីរធំ | ០០ | ០០ | ០០ | ៥៥០ | ០០ | ៥៥០ | |
| ៨ | ភូមិធំ | ៤២ | ៤២ | ០០ | ២៦១ | ២២៣ | ៣៨ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៩ | ព្រែកឯង | ០០ | ០០ | ០០ | ៤៧ | ៤៧ | ០០ | |
| ១០ | ព្រែកថ្មី | ២៣២ | ២៣២ | ០០ | ១៦៦ | ១២១ | ៤៥ | |
| ១១ | សំរោងធំ | ៤៥ | ៤៥ | ០០ | ១៣០០ | ០០ | ១៣០០ | |
| ១២ | វាលស្បូវ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | |
| **សរុប** | | ***៨៨០*** | ***៨៨០*** | ***០០*** | ***៥៤៦១*** | ***២៥២៩*** | ***២៩៣២*** | |

ស្រុកកៀនស្វាយមានអាកាសធាតុក្តៅ មានភ្លៀងដោយកន្លែង ដែលជាឱកាសសម្រាប់ប្រជាពលរដ្ឋធ្វើស្រែចំការ ហើយសំបូររុក្ខជាតិស្មៅងាយស្រួលក្នុងការចិញ្ចឹមសត្វពាហនៈ ។

## ២.២ ទិន្នន័យប្រជាសាស្ត្រ

### ក. ចំនួនប្រជាពលរដ្ឋ

ស្រុកកៀនស្វាយ មានប្រជាជនសរុបចំនួន **31.285** គ្រួសារ មានមនុស្សសរុបចំនួន **161.618** នាក់ ក្នុងនោះមានស្រីចំនួន **91.480** នាក់ មនុស្សប្រុស **80.128** នាក់។ ដង់ស៊ីតេប្រជាជនជាមធ្យមមានចំនួន **410** នាក់ ក្នុង **1** គ.ម២ ហើយដែលមានទំហំគ្រួសារជាមធ្យមស្មើនឹង **5,1** ។ ឃុំដែលមានប្រជាជនច្រើនជាងគេគឺឃុំ សំរោងធំ មានចំនួន **19.769** នាក់ និង ឃុំ គគីរ មានចំនួន **15.716** នាក់ ។ ចំណែកឯឃុំដែលមានប្រជាជនតិចជាងគេគឺឃុំ វាលស្បូវ ដែលមានមនុស្សចំនួន **7.336** នាក់ ។

- **ចំនួនប្រជាជនប្រុស-ស្រី គិតជានាក់ និង តាមលំដាប់អាយុ នៅតាមឃុំនីមួយៗទាំង ១២**

| ល.រ | ឈ្មោះឃុំ | ចំនួនប្រជាជន | | ០-៥ឆ្នាំ | | ៦-១៤ឆ្នាំ | | ១៥-១៧ឆ្នាំ | | ១៨-៦៤ឆ្នាំ | | ៦៥ឆ្នាំឡើងទៅ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| 1 | វាលស្បូវ | 6946 | 3523 | 574 | 279 | 1326 | 625 | 549 | 253 | 4497 | 2366 | 0 | 0 |
| 2 | ព្រែកឯង | 12496 | 6404 | 1031 | 499 | 2523 | 1178 | 1023 | 483 | 7919 | 4244 | 0 | 0 |
| 3 | ក្បាលកោះ | 13234 | 6832 | 1053 | 496 | 2546 | 1252 | 1020 | 470 | 8615 | 4611 | 0 | 0 |
| 4 | ភូមិធំ | 10071 | 5166 | 1039 | 489 | 1991 | 989 | 725 | 354 | 6316 | 3334 | 0 | 0 |
| 5 | គគីរ | 16201 | 8328 | 1634 | 795 | 3264 | 1639 | 1335 | 643 | 9968 | 5251 | 0 | 0 |
| 6 | ដីឥដ្ឋ | 13871 | 7972 | 1322 | 668 | 2653 | 1294 | 1131 | 530 | 8765 | 5480 | 0 | 0 |
| 7 | បន្ទាយដែក | 13607 | 6974 | 1548 | 733 | 2811 | 1381 | 1136 | 556 | 8112 | 4304 | 0 | 0 |
| 8 | សំរោងធំ | 19758 | 10103 | 2272 | 1144 | 4099 | 1959 | 1914 | 745 | 11773 | 6255 | 0 | 0 |
| 9 | គគីរធំ | 12046 | 6264 | 1187 | 608 | 2422 | 1171 | 1034 | 527 | 7403 | 3958 | 0 | 0 |
| 10 | ព្រែកថ្មី | 14488 | 7505 | 1334 | 680 | 2613 | 1277 | 983 | 471 | 9558 | 5077 | 0 | 0 |
| 11 | ឈើទាល | 7809 | 4023 | 869 | 429 | 1699 | 818 | 608 | 309 | 4633 | 2467 | 0 | 0 |
| 12 | កំពង់ស្វាយ | 9083 | 4733 | 883 | 403 | 1675 | 827 | 712 | 303 | 5813 | 3200 | 0 | 0 |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **សរុប** | ***149.610*** | ***77.827*** | ***14.746*** | ***7.223*** | ***29.622*** | ***14.410*** | ***11.870*** | ***5644*** | ***93.372*** | ***50.550*** | | |

ក្នុងតួលេខចំនួនប្រជាជនសរុបខាងលើ ក្នុងនោះមាន :

- ជនជាតិចាម មានចំនួន 23 គ្រួសារ មានមនុស្ស 115 នាក់ ក្នុងនោះស្រី 57 នាក់
- ជនជាតិវៀតណាម មានចំនួន 473 គ្រួសារ មានមនុស្ស 2.691 នាក់ ក្នុងនោះស្រី 1.340 នាក់
- ជនជាតិកម្ពុជាក្រោម មានចំនួន 85 គ្រួសារ មានមនុស្ស 514 នាក់ ក្នុងនោះស្រី 222 នាក់

## ខ. មុខរបរសំខាន់របស់ប្រជាជន

- គ្រួសារ 20.344 : 65.02 % ប្រកបរបរកសិកម្ម (ដាំដុះ ចិញ្ចឹមសត្វ និងនេសាទ)
- គ្រួសារ 168 : 0.54 % ប្រកបមុខរបរសិប្បកម្ម លក់ដូរ ផលិតកម្ម
- គ្រួសារ 3.733 : 11.93 % ប្រកបមុខរបរសេវាកម្ម (ជំនាង, ជំនួញ...)
- គ្រួសារ 7.040 : 22.50 % ជាមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ

## គ. កំរិតវប្បធម៌

- ចំនួនសិស្សសរុប

| **ប្រភេទសិស្ស** | **សរុប (នាក់)** | **ស្រី (នាក់)** | **ប្រុស (នាក់)** |
|---|---|---|---|
| មត្តេយ្យ | 1649 | 837 | 812 |
| បឋមសិក្សា | 22878 | 10754 | 12124 |
| មធ្យមសិក្សាបឋមភូមិ | 10344 | 4891 | 5453 |
| មធ្យមសិក្សាទុតិយភូមិ | 3859 | 1593 | 226 |
| **សរុប** | ***38730*** | ***18075*** | ***20655*** |

- អ្នកមិនចេះអក្សរ និង កុមារមិនបានចូលរៀន

| **ល.រ** | **ឈ្មោះឃុំ** | **អនក្ខរជន ១៥-៤៥ ឆ្នាំ** | | **កុមារមិនបានចូលរៀន ០៦-១៤ ឆ្នាំ** | |
|---|---|---|---|---|---|
| | | **សរុប (នាក់)** | **ស្រី (នាក់)** | **សរុប (នាក់)** | **ស្រី (នាក់)** |
| 1 | វាលស្បូវ | 326 | 240 | 25 | 19 |
| 2 | ព្រែកឯង | 393 | 259 | 30 | 23 |
| 3 | ក្បាលកោះ | 1294 | 876 | 30 | 21 |
| 4 | ភូមិធំ | 735 | 545 | 20 | 10 |
| 5 | គគីរ | 1191 | 812 | 25 | 19 |
| 6 | ដីឥដ្ឋ | 558 | 737 | 15 | 05 |
| 7 | បន្ទាយដែក | 1232 | 866 | 45 | 19 |

| | | | | | |
|---|---|---|---|---|---|
| 8 | សំរោងធំ | 1864 | 1288 | 30 | 17 |
| 9 | គគីរធំ | 2192 | 1300 | 30 | 25 |
| 10 | ព្រែកថ្មី | 700 | 495 | 13 | 07 |
| 11 | ឈើទាល | 822 | 511 | 14 | 08 |
| 12 | កំពង់ស្វាយ | 1468 | 846 | 13 | 07 |
| **សរុប** | | **12775** | **8775** | **290** | **180** |

## ឃ. សេដ្ឋកិច្ច

❑ **កម្រិតអត្រានៃភាពក្រីក្រ**

អ្នកក្រីក្រ មាន 40%, អ្នកមធ្យម មាន 35% និង អ្នកធូរធារគ្រាន់បើ មាន 25% ។

❑ **ចំនួនស្ត្រីជាមេគ្រួសារ**

ចំនួនស្ត្រីជាមេគ្រួសារដែលមានកូនអាយុតិចជាង៥ឆ្នាំមានចំនួន 408 គ្រួសារ ស្មើនឹង 1,34% នៃគ្រួសារសរុប 30.446 គ្រួសារ ។

❑ **កម្លាំងពលកម្ម**

កម្លាំងពលកម្មពីអាយុ 17ឆ្នាំ ដល់ 55ឆ្នាំ មាន 78.024 នាក់ ក្នុងនោះស្រី 43.116 នាក់ ។

❑ **សកម្មភាពនៃចំណូល**

- ប្រជាជនក្រីក្រសរុប ៦៥% ក្នុងនោះមាន ៣៥% រកចំណូល បានតិចជាង 1.000៛ក្នុង១ថ្ងៃ រីឯ ៣៥% ទៀត អាចរកចំណូលបានពី 2.000៛ ទៅ3.000៛ ក្នុង១ថ្ងៃ
- អ្នកក្រមធ្យម ៧,៥ % អាចរកចំណូលបានពី 3.000៛ ទៅ 4.000៛ក្នុង១ថ្ងៃ
- អ្នកគ្រាន់បើ អាចរកចំណូលបានពី 4.000៛ ទៅ 6.000៛ក្នុង១ថ្ងៃ ដោយឡែកអ្នកលក់ដូរ អាជីវករ
- សិប្បករ អាចរកចំណូលបានពី 8.000៛ យ៉ាងតិចក្នុង១ថ្ងៃ ។

❑ **ចំណាកស្រុក**

ដោយគ្រោះធម្មជាតិ ទឹកជំនន់ និងរាំងស្ងួត ជួន១ជាប់គ្នា៣ឆ្នាំ ធ្វើឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយការបង្កបង្កើនផលត្រូវចំណាយទុនច្រើន រីឯផលប្រមូលផលបានតិចតួច បាត់តុល្យភាពទុន រវាងការដាំដុះ ទៅនឹងផលដែលបានទទួល ធ្វើឱ្យប្រជាជនយើងជួបនូវការខ្វះខាតស្បៀង ក្នុងនោះគ្រួសារប្រជាកសិករមួយ ចំនួនត្រូវខ្ចីបុល ចងការប្រាក់សម្រាប់ចំណាយឱ្យការងារបង្កបង្កើនផលបន្ត។ កត្តានេះបានជះឥទ្ធិពលដល់កិរិតនៃការលើក កំពស់ជីវភាពប្រជាជន បានជំរុញឱ្យប្រជាជនមួយចំនួនត្រូវបង្ខំចិត្តលក់ដីដើម្បីដោះបំណុល រួចទៅប្រកបមុខរបរសេវាកម្ម ស៊ីឈ្នួលគេ និងមួយចំនួនត្រូវចំណាកស្រុកទៅតំបន់ឆ្ងាយ សរុបចំនួន 2.310 នាក់ ក្នុងនោះស្រី 1.604 នាក់ដើម្បីរកមុខរបរ សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ។

## ២.៣ ប្រវត្តិគ្រោះមហន្តរាយ

ស្រុកកៀនស្វាយស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គ ទន្លេបាសាក់ និងមានព្រែកជាច្រើនហូរឆ្លងកាត់ជាតំបន់ទំនាប ដែលងាយនឹងទទួលរងគ្រោះខ្លាំង ពីទឹកជំនន់ទន្លេមេគង្គ និងទន្លេបាសាក់ ។ ដោយសារស្រុកមានទីតាំងភូមិសាស្ត្រ បែបនេះ ទើបទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយទឹកទន្លេមេគង្គ និងទន្លេបាសាក់ ជាប់ៗគ្នា ឆ្នាំ ២០០០-២០០១-២០០២ ។

### ក. ការវិភាគមុខសញ្ញាបង្កគ្រោះថ្នាក់នានាពីឆ្នាំ១៩៩៩-២០០៦

| មុខសញ្ញា | ឥទ្ធិពល និង ភាពធ្ងន់ធ្ងរ | | | | | | | | ពេលវេលា | រយៈពេល | ល្បឿន | គ្រោះថ្នាក់ដែលអាចកើតឡើង |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៩៩៩ | ២០០០ | ២០០១ | ២០០២ | ២០០៣ | ២០០៤ | ២០០៥ | ២០០៦ | | | | |
| ទឹកជំនន់ | x | xxx | xx x | x x | x | x | x | xx | កក្កដា-តុលា | ០៥ ខែ | យឺតៗ | - មនុស្ស<br>- ដំណាំកសិកម្ម និង ឧស្សាហកម្ម<br>- សត្វ<br>- ហេដ្ឋារចនាសម្ព័ន្ធ និង អាគារ |
| រាំងស្ងួត | x | x | x | x | xx | xxx | x | xx | មករា-មេសា | ០៤ ខែ | យឺតៗ | - សត្វ ( មានជំងឺរាតត្បាត)<br>- ដំណាំកសិកម្ម និង ឧស្សាហកម្ម |
| ខ្យល់ព្យុះ | | x | x | x | x | x | x | xx | | | លឿន | - មនុស្ស និង សត្វ<br>- អាគារ ផ្ទះ និង ហេដ្ឋារចនាសម្ព័ន្ធ |

*កំណត់សម្គាល់ :*

- xxx ធំ
- x x មធ្យម
- x តូច ឬស្រាល

មូលដ្ឋានដែលងាយរងគ្រោះដោយទឹកជំនន់ មានទាំង១២ឃុំ ក្នុងនោះប៉ះពាល់ធ្ងន់ធ្ងរជាងគេ មាន៦ឃុំ គឺ ឃុំបន្ទាយដែក, ក្បាលកោះ, គគីរ, គគីរធំ, ភូមិធំ, និង ឃុំសំរោងធំ ។

### ខ. ការវិភាគភាពងាយរងគ្រោះ

ទូទាំងស្រុកកៀនស្វាយ ចំនួនអ្នកងាយទទួលរងពីឥទ្ធិពលនៃគ្រោះមហន្តរាយមាន 7.435គ្រួសារ ស្មើនឹង 42.379នាក់ ក្នុងនោះមានកុមារ 5.172នាក់ ចាស់ជរា 705នាក់ ស្ត្រីមេម៉ាយ 392នាក់ ហើយមានឃុំចំនួន ៩ ដែលងាយរងគ្រោះជាងគេ គឺឃុំ ភូមិធំ គគីរ សំរោងធំ គគីរធំ ព្រែកថ្មី ឈើទាល ដីឥដ្ឋ បន្ទាយដែក ក្បាលកោះ

| ល.រ | ឈ្មោះឃុំ | ទំនប់ទឹក (ម៉ែត្រ) | ប្រលាយ (ម៉ែត្រ) | សាលារៀន (កន្លែង) | មណ្ឌលសុខភាព (កន្លែង) | វត្តអារាម (ចំនួន) | អាគារ (ចំនួន) | ផ្លូវថ្នល់ (ម៉ែត្រ) |
|---|---|---|---|---|---|---|---|---|
| 1 | បន្ទាយដែក | 2450 | 2025 | 00 | 00 | 01 | 00 | 2125 |
| 2 | ឈើទាល | 3260 | 2350 | 00 | 00 | 00 | 00 | 1790 |
| 3 | ដីឥដ្ឋ | 3990 | 2895 | 00 | 00 | 02 | 00 | 3570 |
| 4 | កំពង់ស្វាយ | 3195 | 2530 | 00 | 00 | 01 | 00 | 2915 |
| 5 | ក្បាលកោះ | 1920 | 1750 | 00 | 00 | 00 | 00 | 2875 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **6** | គគីរ | 2790 | 1865 | 00 | 00 | 02 | 00 | 2990 |
| **7** | គគីរធំ | 3980 | 3125 | 00 | 00 | 02 | 00 | 2980 |
| **8** | ភូមិធំ | 2875 | 2095 | 00 | 00 | 02 | 00 | 3850 |
| **9** | ព្រែកឯង | 00 | 1993 | 00 | 00 | 00 | 00 | 1520 |
| **10** | ព្រែកថ្មី | 2595 | 2029 | 00 | 00 | 02 | 00 | 3015 |
| **11** | សំរោងធំ | 4897 | 4695 | 00 | 00 | 01 | 00 | 7390 |
| **12** | វាលស្បូវ | 2515 | 1775 | 00 | 00 | 02 | 00 | 2978 |
| ***សរុប*** | | ***34467*** | ***29127*** | ***00*** | ***00*** | ***15*** | ***00*** | ***37998*** |

## គ.  ផែនទីគ្រោះមហន្តរាយទឹកជំនន់ឆ្នាំ២០០០  របស់ស្រុកកៀនស្វាយ



## ២.៤. ធនធានផ្សេងៗ

### ក. ទិន្នន័យសាលារៀន និង សិស្ស (ស្ថិតិសិក្សាឆ្នាំ ២០០៦-២០០៧)

| ល.រ | ឈ្មោះឃុំ | បឋមសិក្សា | | | | អនុវិទ្យាល័យ | | | | វិទ្យាល័យ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | កន្លែង | បន្ទប់ | គ្រូ | សិស្ស | កន្លែង | បន្ទប់ | គ្រូ | សិស្ស | កន្លែង | បន្ទប់ | គ្រូ | សិស្ស | |
| 1 | បន្ទាយដែក | 04 | 48 | 53 | 2341 | 01 | 05 | 26 | 878 | 00 | 00 | 00 | 00 | |
| 2 | ឈើទាល | 05 | 50 | 42 | 1711 | 01 | 05 | 16 | 291 | 00 | 00 | 00 | 00 | |
| 3 | ដីឥដ្ឋ | 03 | 56 | 82 | 2564 | 00 | 00 | 00 | 00 | 01 | 53 | 00 | 3059 | |
| 4 | កំពង់ស្វាយ | 03 | 36 | 38 | 1454 | 00 | 00 | 00 | 00 | 01 | 24 | 39 | 1158 | |
| 5 | ក្បាលកោះ | 05 | 85 | 88 | 2183 | 01 | 05 | 31 | 813 | 00 | 00 | 00 | 00 | |
| 6 | គគីរ | 05 | 75 | 85 | 2752 | 01 | 11 | 36 | 1232 | 00 | 00 | 00 | 00 | |
| 7 | គគីរធំ | 04 | 56 | 69 | 2148 | 01 | 39 | 35 | 902 | 00 | 00 | 00 | 00 | |
| 8 | ភូមិធំ | 04 | 45 | 50 | 1650 | 01 | 05 | 30 | 754 | 00 | 00 | 00 | 00 | |
| 9 | ព្រែកឯង | 03 | 42 | 82 | 2135 | 00 | 00 | 00 | 00 | 01 | 39 | 131 | 2293 | |
| 10 | ព្រែកថ្មី | 03 | 54 | 78 | 2203 | 01 | 18 | 39 | 771 | 00 | 00 | 00 | 00 | |
| 11 | សំរោងធំ | 06 | 84 | 85 | 3186 | 01 | 19 | 39 | 902 | 00 | 00 | 00 | 00 | |
| 12 | វាលស្បូវ | 02 | 00 | 43 | 835 | 01 | 10 | 21 | 350 | 00 | 00 | 00 | 00 | |
| **សរុប** | | ***47*** | ***631*** | ***795*** | ***25162*** | ***09*** | ***117*** | ***273*** | ***6893*** | ***03*** | ***116*** | ***170*** | ***6510*** | |

### ខ. មណ្ឌលសុខភាព និង មន្ទីរពេទ្យ

ទូទាំងស្រុក មានមណ្ឌលសុខភាពចំនួន 10 កន្លែង មានបុគ្គលិក 196 នាក់ មានវេជ្ជបណ្ឌិត 04 នាក់ គ្រូពេទ្យមធ្យម 04 នាក់ ពេទ្យបឋម និងគិលានុប្បដ្ឋាយិកា។ ដោយឡែកនៅគ្រប់ឃុំ មានឆ្មបបុរាណដែលបានទទួលការណែនាំបណ្តុះបណ្តាលពីអ្នកជំនាញ។ ព្រមទាំងមានសេវាផ្សព្វផ្សាយអំពី សុខភាព អនាម័យ ជំងឺឆ្លង ជំងឺរាតត្បាតផ្សេងៗ និងក្រុមចុះ ចាក់វ៉ាក់សាំង ៧មុខ ដល់ទារកកុមារ តាមជនបទទៀតផង។

| ល.រ | ឈ្មោះមណ្ឌលសុខភាព | ចំនួនបុគ្គលិក |
|---|---|---|
| 1 | | 08 |
| 2 | ក្បាលកោះ | 08 |
| 3 | ភូមិធំ | 07 |
| 4 | ដីឥដ្ឋ | 06 |
| 5 | បន្ទាយដែក | 08 |
| 6 | សំរោងធំ | 07 |

| | | |
|---|---|---|
| 7 | គគីរធំ | 07 |
| 8 | ព្រែកថ្មី | 05 |
| 9 | ឈើទាល | 04 |
| 10 | កំពង់ស្វាយ | 06 |
| **សរុបះ** | | **66** |

## គ. ទីទួលសុវត្ថិភាព និង ទីតាំង

ជារួមស្រុកកៀនស្វាយ ពុំមានទីទួលសុវត្ថិភាពឱ្យបានត្រឹមត្រូវតាមកម្រិតស្តង់ដារឡើយ ប៉ុន្តែស្រុកបានកំណត់យកទីទួលសុវត្ថិភាពនៅតាមទីសាធារណៈរួមមានៈ សាលារៀន, វត្តអារាម ១៩កន្លែង នៅគ្រប់ឃុំសម្រាប់បម្រើជាកន្លែងស្នាក់នៅបណ្តោះអាសន្នក្នុងពេលមានទឹកជំនន់ ដោយឡែកនៅមានទីទួលសុវត្ថិភាពតាមគ្រួសារខ្លះក្នុងឃុំគគីរ បន្ទាយដែក សំរោងធំ គគីរធំ ដែលបានរៀបចំបង្កើតដោយកាកបាទ ក្រហមកម្ពុជាខេត្តសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

## ឃ. មធ្យោបាយដឹកជញ្ជូន

| ល.រ | ឈ្មោះឃុំ | ម៉ូតូ/ ម៉ូតូរ៉ឺម៉ក | ត្រាក់ទ័រ គោយន្ត រថយន្ត | រទេះសេះ រទេះគោ | កង់/កង់រ៉ឺម៉ក | ទូកចែវ ទូកអុំ | ទូកម៉ាស៊ីន ណូត |
|---|---|---|---|---|---|---|---|
| 1 | បន្ទាយដែក | 228 | 43 | 35 | 123 | 46 | 37 |
| 2 | ឈើទាល | 215 | 39 | 28 | 215 | 23 | 21 |
| 3 | ដីឥដ្ឋ | 305 | 119 | 33 | 392 | 28 | 39 |
| 4 | កំពង់ស្វាយ | 223 | 45 | 39 | 308 | 32 | 29 |
| 5 | ក្បាលកោះ | 220 | 126 | 34 | 315 | 35 | 36 |
| 6 | គគីរ | 260 | 137 | 42 | 360 | 43 | 41 |
| 7 | គគីរធំ | 194 | 35 | 47 | 222 | 39 | 45 |
| 8 | ភូមិធំ | 218 | 39 | 25 | 174 | 27 | 41 |
| 9 | ព្រែកឯង | 225 | 106 | 28 | 316 | 29 | 30 |
| 10 | ព្រែកថ្មី | 221 | 52 | 31 | 295 | 34 | 29 |
| 11 | សំរោងធំ | 227 | 142 | 42 | 298 | 39 | 43 |
| 12 | វាលស្បូវ | 195 | 59 | 15 | 179 | 28 | 27 |
| **សរុប** | | ***2731*** | ***942*** | ***399*** | ***3233*** | ***403*** | ***418*** |

## ង. ប្រព័ន្ធធារាសាស្ត្រ

ទូទាំងស្រុកមានប្រព័ន្ធធារាសាស្ត្រ ទំនប់ ប្រឡាយ នៅគ្រប់ឃុំ សរុបមាន ប្រឡាយព្រែកចំនួន ៨5ខ្សែ ដែលអាចស្រោចស្រពលើផ្ទៃដីបង្កបង្កើនផលរបស់ប្រជាកសិករនៅគ្រប់រដូវ ។

- **ទន្លេសំខាន់ៗ :**

ស្រុកកៀនស្វាយស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គ ទន្លេបាសាក់ និងមានព្រែកជាច្រើនហូរឆ្លងកាត់ជាតំបន់ទំនាប ។

- **ប្រភពទឹកផ្សេងៗទៀត :**

ក្នុងភូមិសាស្ត្ររបស់ស្រុក មានទំនាបបឹង អូរ និងស្ទឹង ដែលជាជម្រកសម្រាប់ត្រីពង កូន បង្កើនធនធានមច្ឆាគ្រប់ប្រភេទ ហើយក៏ជាថ្នក់សម្រាប់តំកល់ទឹកទុក សម្រាប់ប្រើប្រាស់ ស្រោចស្រពផ្ទៃដីបង្កបង្កើនផលផងដែរ ។

## ច. ប្រព័ន្ធទំនាក់ទំនង

- **អង្គការនានានៅក្នុងស្រុក**

ស្រុកកៀនស្វាយ មានអង្គការក្រៅរដ្ឋាភិបាល ជាតិ និងអន្តរជាតិមួយចំនួនកំពុងធ្វើសកម្មភាពលើគម្រោងកម្មវិធី របស់ខ្លួន រួមមាន: សមាគមចិន, ស្ថាបនា, សារព័ត៌មានសហគមន៍ (KAD), PRASAC, ADPC, Amreth ( EMT), ACLEDA ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្ដាល

សាលាស្រុកកៀនស្វាយ

## បញ្ជីរាយនាមឈ្មោះថ្នាក់ដឹកនាំស្រុក ការិយាល័យជំនាញជុំវិញស្រុក និងមេឃុំ

| ល.រ | នាម_គោត្តនាម | ភេទ | តួនាទី_ការិ.អង្គភាព | លេខទូរសព្ទ័ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ហេង ធឿម | ប | អភិបាលស្រុក | ០១២-២៧២ ៧២០ | |
| ២ | ទ៉ាម ទាសនា | ស | ប្រធានការិយាល័យរដ្ឋបាល | ០៩២-៨៧៧ ៧០៦ | |
| ៣ | នៅ ស៊ីម៉ុន | ប | ប្រធានការិយាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១១-៧០០ ១៧១ | |
| ៤ | ចាន់ សាធុន | ប | ប្រធានការិយាល័យអប់រំ យុវជន និងកីឡា | ០៩២-៥៤៤ ៤១០ | |
| ៥ | ប៉ែន សំអឿន | ប | ប្រធានការិយាល័យកសិកម្ម | ០១២-៦៣៥ ៧០៤ | |
| ៦ | ថោង សារិទ្ធ | ប | ប្រធានការិយាល័យបរិស្ថាន | ០១១-៤៩៣ ៣៧៥ | |
| ៧ | ហែន ធុន្ធា | ប | អនុប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល | ០១២-៨៥១ ៣២៥ | |
| ៨ | ចាន់ ធុន្ធា | ប | ប្រធានការិយាល័យសាធារណៈការ | ០១១-៨៨១ ៧០២ | |
| ៩ | ហ៊ីង សៅគុន | ប | ប្រធានការិយាល័យវប្បធម៌ | ០១២-៥៩២ ១២០ | |
| ១០ | សៀ ពិភេត | ស | ប្រធានការិយាល័យកិច្ចការនារី | ០១២-៩៨៦ ២១០ | |
| ១១ | នង សុវណ្ណា | ប | ប្រធានការិយាល័យសុខាភិបាល | ០១២-៨៨៥ ៥៣៦ | |
| ១២ | គង់ ស្សាដឿន | ប | ប្រធានការិយាល័យប្រៃសនីយ៍ | ០៩២-៩៣៨ ០២៧ | |
| ១៣ | លាត សារឿន | ប | ប្រធានការិយាល័យសង្គមកិច្ច | ០១៦-៨៩២ ៣២២ | |
| ១៤ | ប្រាជ្ញ សុវណ្ណរិទ្ធ | ប | ប្រធានការិយាល័យធនធានទឹក | ០១២-៥៩១ ៣៤៩ | |
| ១៥ | ចេង សុខ | ប | មេបញ្ជាការផ្នែកសឹករងស្រុក | ០៩២-៧៤៥ ៧៦៦ | |
| ១៦ | អ៊ីន សុផាត | ប | មេបញ្ជាការកងរាជអាវុធហត្ថស្រុក | ០១២-២៦៩ ៥៩៥ | |
| ១៧ | ង៉ា សំអិត | ប | អធិការនគរបាលស្រុក | ០១២-៩១៥៧៨៥ | |
| ១៨ | អ៊ុយ សារធ | ប | មេឃុំវាលស្បូវ | ០៩២-២៧៨ ៥៧៥ | |
| ១៩ | នេត សារ៉ែន | ប | មេឃុំព្រែកឯង | ០១២- ៩២៧ ៩៩៤ | |

| | | | | | |
|---|---|---|---|---|---|
| ២០ | ហោ ទេវ៉ាណែ | ប | មេឃុំក្បាលកោះ | ០១២-៧៣៦ ០៧៦ | |
| ២១ | មៀច ផៃ | ប | មេឃុំភូមិធំ | ០១១-៨៨០ ៧៦៩ | |
| ២២ | គង់ ឆេង | ប | មេឃុំគគីរ | ០៩២-៨១៧ ៧៦៦ | |
| ២៣ | ស៊ិត តូ | ប | មេឃុំដីឥដ្ឋ | ០១២-៧៣៦ ៨៣៣ | |
| ២៤ | យួន គង់ | ប | មេឃុំបន្ទាយដែក | ០១២-៨៣៧ ៧១៧ | |
| ២៥ | ម៉ិត ចន្ថា | ស | មេឃុំសំរោងធំ | ០១១-៩៨២ ២៦៥ | |
| ២៦ | នុត សារ៉ុន | ប | មេឃុំគគីរធំ | ០១២-៤៥២ ៣៦៦ | |
| ២៧ | កុយ ណារ៉ុង | ប | មេឃុំកំពង់ស្វាយ | ០១២-៧១៧ ៦៨១ | |
| ២៨ | ម៉ែន ខុង | ប | មេឃុំឈើទាល | ០៩២-៩០៩ ៩៨១ | |
| ២៩ | ឈឹម សារ៉េង | ប | មេឃុំព្រែកថ្មី | ០៩២-២៦៧ ៤៤៧ | |

## ៣. ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

### ៣.១ ក្របខណ្ឌការងារនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

ផែនការសកម្មភាពដែលបានលើកឡើងដោយផ្អែកលើក្របខ័ណ្ឌការងារសកម្មភាពយោហ្គោ(HFA) គឺបានរៀបចំក្នុងគម្រោងការគ្រប់ជ្រុងជ្រោយមួយដើម្បីចង្អុលណែនាំអំពីការឆ្លើយតបរបស់អ្នកពាក់ព័ន្ធលើការដោះស្រាយផលប៉ះពាល់នៃគ្រោះមហន្តរាយ ។ ប៉ុន្តែការសង្កត់ធ្ងន់ត្រូវបានតម្រង់ទៅរកការពង្រឹងសមត្ថភាពថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់មូលដ្ឋានសហគមន៍ ដោយកំណត់ទិសដៅឱ្យបានច្បាស់លាស់សម្រាប់ការផ្តួចផ្តើម ការកាត់បន្ថយ គ្រោះភ័យនៃគ្រោះមហន្តរាយ និងដើម្បីគាំទ្រដល់ការសម្រេចឱ្យបាននូវ គោលបំណងកាត់បន្ថយភាពក្រីក្រ របស់ប្រទេស ដែលមាននៅក្នុងផែនការ និងគោលនយោបាយជាតិ(NSDP) ២០០៦-២០១០, NPRS, CMDG, NAPA ២០០៦) ។

សមាសភាគនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយមានចំនួន ០៦សំខាន់ ដែលបានកំណត់ជាអាទិភាព សម្រាប់ប្រទេសកម្ពុជា ដូចខាងក្រោម :

**១-ធានាឱ្យបាននូវការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ គឺជាអាទិភាពនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន**

១.១-រៀបចំដាក់លាក់គោលនយោបាយជាតិ និង នីតិកម្ម ក្នុងការគាំទ្រដល់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

១.២-បង្កើត និងពង្រឹងយន្តការសម្របសម្រួលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅថ្នាក់ជាតិ ឬ"កម្មវិធីជាតិស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ"

១.៣-សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងផែនការ និងគោលនយោបាយ

អភិវឌ្ឍជាតិ

១.៤-ចាត់ចំណាយធនធានសមស្រប សម្រាប់ការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅថ្នាក់ជាតិ ។

**២- ពង្រឹងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានសហគមន៍**

២.១-វិមជ្ឈការការទទួលខុសត្រូវ និងធនធានសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

២.២-លើកកម្ពស់ការអនុវត្ត កម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ ។

**៣- កំណត់ ប៉ាន់ប្រមាណ និងតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ និងលើកកម្ពស់ការផ្តល់ដំណឹងជាមុន**

៣.១-ធ្វើការប៉ាន់ប្រមាណ ពីគ្រោះភ័យនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

៣.២-បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ

៣.៣-កសាងប្រព័ន្ធផ្តល់ដំណឹងជាមុនពីពហុមុខសញ្ញាគ្រោះថ្នាក់

៣.៤-សហការជាមួយ អង្គការអន្តរជាតិ និង អង្គការថ្នាក់តំបន់ លើកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយ គ្រោះ ភ័យនៃគ្រោះមហន្តរាយ ។

**៤- ប្រើប្រាស់ចំណេះដឹង ការរកឃើញថ្មី និងការអប់រំ ដើម្បីកសាងវប្បធម៌សុវត្ថិភាពនិងសមត្ថភាព ទប់ទល់បាន នៅគ្រប់ថ្នាក់**

៤.១-បង្កើតយន្តការសម្រាប់បណ្តាញការងារ និងការផ្លាស់ប្តូរព័ត៌មាន

៤.២-លើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលអំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

៤.៣-លើកកម្ពស់ការបណ្តុះបណ្តាល យេនឌ័រ និងវប្បធម៌ភាពរហ័សរហួន ដែលជាសមាសភាគរួមរបស់ ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

៤.៤-ដំណើរការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និង បច្ចេកទេសអំពីការគ្រប់គ្រងគ្រោះភ័យនៃគ្រោះ មហន្តរាយ

៤.៥-បង្កើនការយល់ដឹងជាសាធារណៈ ។

**៥- ការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីនានា របស់ក្រសួងពាក់ព័ន្ធ**

៥.១-រួមបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និង និរន្តរភាពបរិស្ថាន

៥.២-សមាហរណកម្មការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងកម្មវិធីសកម្មភាពជាតិ បន្សាំនឹងការប្រែប្រួលអាកាសធាតុ

៥.៣-បង្កើនសន្តិសុខស្បៀងដើម្បីបង្កើនសមត្ថភាពធន់ទ្រាំរបស់សហគមន៍

៥.៤-ធ្វើសមាហរណកម្មផែនការការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងវិស័យសុខាភិបាល

៥.៥-លើកកម្ពស់ការកាត់បន្ថយគ្រោះថ្នាក់តាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធឱ្យបានសមស្រប

៥.៦-រួមបញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការធ្វើផែនការប្រើប្រាស់ដីធ្លី និង វិធានការបច្ចេកទេសផ្សេងៗទៀត

៥.៧-បង្កើតទម្រង់បែបបទហិរញ្ញវត្ថុសម្រាប់ការដោះស្រាយគ្រោះភ័យនៃគ្រោះមហន្តរាយ

**៦-ពង្រឹងការត្រៀមរៀបចំសម្រាប់ឆ្លើយតបគ្រោះមហន្តរាយឱ្យមានប្រសិទ្ធភាពនៅគ្រប់ថ្នាក់**

៦.១-ពង្រឹងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការត្រៀមរៀបចំ និងឆ្លើយតប

៦.២-បង្កើតនូវយន្តការប្រតិបត្តិការសម្របសម្រួលថ្នាក់តំបន់ សម្រាប់ការងារសង្គ្រោះបន្ទាន់ ដែល ហួសពីសមត្ថភាពដោះស្រាយនៅថ្នាក់ជាតិ

៦.៣-រៀបចំ និងធ្វើបច្ចុប្បន្នភាពតាមពេលវេលាលើការរៀបចំផែនការបម្រុងទុក និងការត្រៀមរៀបចំ សម្រាប់គ្រោះមហន្តរាយ

៦.៤-បង្កើតឱ្យមានមូលនិធិសង្គ្រោះបន្ទាន់ ។

## ៣.២ តារាងសង្ខេបគម្រោងអាទិភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ

| សមាសភាគនៃការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ | | រយៈពេល | | | ថវិកាដាក់លាក់សម្រាប់រយៈពេលខ្លី(000ដុល្លារ) |
|---|---|---|---|---|---|
| | | S | M | L | |
| 1 | **ធានាឱ្យបាននូវ DRR គឺជាអាទិភាពនៅថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន ប្រកបដោយគ្រឹះនៃស្ថាប័នរឹងមាំសម្រាប់ការអនុវត្តន៍** | | | | |
| 1.1 | រៀបចំដាក់លាក់គោលនយោបាយជាតិ និងនីតិកម្មគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយ ថ្នាក់ជាតិ | * | | | 100 |
| 1.2 | ការបង្កើត និងពង្រឹងយន្តការសម្របសម្រួល DRR ថ្នាក់ជាតិ - កម្មវិធីជាតិស្តីពី DRR | * | | | 300 |
| 1.3 | សមាហរណកម្ម DRR ទៅក្នុងគោលនយោបាយ និងការរៀបចំផែនការអភិវឌ្ឍជាតិ | * | | | 100 |
| 1.4 | ការចាត់ចំណាយធនធានសមស្របសម្រាប់ការងារ DRR នៅថ្នាក់ជាតិ | | | | |
| 2 | **ពង្រឹងការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋានសហគមន៍** | | | | |
| 2.1 | វិមជ្ឈការនៃការទទួលខុសត្រូវ និងធនធានសម្រាប់ DRR | | | | |
| 2.2 | លើកកម្ពស់ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋាន-សហគមន៍ | | | | 550 |
| 3 | **កំណត់ ប៉ាន់ប្រមាណ និងតាមដានត្រួតពិនិត្យមុខសញ្ញាគ្រោះថ្នាក់ និង លើកកម្ពស់ការផ្តល់ដំណឹងជាមុន** | | | | |
| 3.1 | ដំណើរការប៉ាន់ប្រមាណគ្រោះភ័យថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន | | | | |
| 3.2 | បង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ | | | | |
| 3.3 | កសាងប្រព័ន្ធផ្តល់ដំណឹងជាមុនពីពហុមុខសញ្ញាគ្រោះថ្នាក់ | | | | |
| 3.4 | សហប្រតិបត្តិការជាមួយ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិនៃកិច្ចខិតខំប្រឹងប្រែងលើ DRR | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| 4 | **ប្រើប្រាស់ចំណេះដឹង ការរកឃើញថ្មី និងការអប់រំដើម្បីកសាងវប្បធម៌សុវត្ថិភាព និង សមត្ថភាពទប់ទល់បាននៅគ្រប់ថ្នាក់** | | | | | |
| 4.1 | បង្កើតយន្តការសម្រាប់បណ្តាញការងារ និងផ្លាស់ប្តូរព័ត៌មាន | | | | | |
| 4.2 | លើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលអំពី DRR | | | | | |
| 4.3 | លើកកម្ពស់ការបណ្តុះបណ្តាលពីយិនឌ័រ និងវប្បធម៌ភាពរហ័សរហួន ដែលជាសមាសភាគរួម របស់ DRR | | | | | |
| 4.4 | ផ្តើមធ្វើការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងបច្ចេកទេសអំពីការគ្រប់គ្រង DRR | | | | | |
| 4.5 | បង្កើនការយល់ដឹងជាសាធារណៈ | | | | | |
| 5 | **បញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់ក្រសួងពាក់ព័ន្ធ** | | | | | |
| 5.1 | រួមបញ្ចូល DRR ទៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព | | | | | |
| 5.2 | សមាហរណកម្មការងារ DRR ទៅក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួល អាកាសធាតុ | | | | | |
| 5.3 | បង្កើនសន្តិសុខស្បៀងដើម្បីលើកកម្ពស់សមត្ថភាពអាចទប់ទល់បានរបស់សហគមន៍ | | | | | |
| 5.4 | លើកកម្ពស់ការកាត់បន្ថយគ្រោះថ្នាក់តាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធឱ្យបាន សមស្រប | | | | | |
| 5.5 | សមាហរណកម្មការធ្វើផែនការ DRR ទៅក្នុងវិស័យសុខាភិបាល | | | | | |
| 5.6 | រួមបញ្ចូល DRR ទៅក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លីនិងវិធានការបច្ចេកទេសដទៃទៀត | | | | | 150 |
| 5.7 | បង្កើតទម្រង់បែបបទឯកសារហិរញ្ញវត្ថុសម្រាប់ដោះស្រាយគ្រោះភ័យនៃគ្រោះមហន្តរាយ | | | | | |
| 6 | **ពង្រឹងការត្រៀមរៀបចំសម្រាប់ការឆ្លើយតបគ្រោះមហន្តរាយ ឱ្យមានប្រសិទ្ធភាពនៅគ្រប់ថ្នាក់** | | | | | |
| 6.1 | ពង្រឹងសមត្ថភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការត្រៀមរៀបចំ និងការឆ្លើយតប | | | | | 400 |
| 6.2 | បង្កើតយន្តការប្រតិបត្តិការ សម្របសម្រួលសម្រាប់ការសង្គ្រោះបន្ទាន់ ដែលហួសសមត្ថភាព ដោះស្រាយនៅថ្នាក់ជាតិ | | | | | |
| 6.3 | រៀបចំ និងធ្វើបច្ចុប្បន្នភាពតាមដំណាក់កាលលើការត្រៀមរៀបចំសម្រាប់គ្រោះមហន្តរាយ និង ផែនការបម្រុងទុកជាមុន | | | | | |
| 6.4 | បង្កើតឱ្យមានមូលនិធិសង្គ្រោះបន្ទាន់ | | | | | |
| | **សរុបរួម** | | | | | 2,000 |

***កំណត់សម្គាល់ :***

- ***** - កម្មវិធីត្រូវអនុវត្តបន្ទាន់ (ឆ្នាំទី១)
- **S** - កម្មវិធីរយៈពេលខ្លី (១-២ ឆ្នាំ)
- **M** - កម្មវិធីរយៈពេលមធ្យម (៣-៤ ឆ្នាំ)
- **L** – កម្មវិធីរយៈពេលវែង (៥-៧ ឆ្នាំ )

# ៤. យន្តការស្ថាប័ន និង ការគ្រប់គ្រងគ្រោះមហន្តរាយ

## ៤.១ សមាសភាព

១. អភិបាល ស្រុក ជាប្រធាន

២. អភិបាលរងស្រុក ជាអនុប្រធាន

៣. កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទ និងការិយាល័យជុំវិញស្រុក ជាសមាជិក

៤. ប្រធានមន្ទីរសាលាស្រុក ជាលេខាអចិន្ត្រៃយ៍ និង ប្រធានការិយាល័យចំនួន ០៣រូប ជាជំនួយការ ។

## ៤.២ តួនាទី និង ការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក

ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក មានតួនាទីដឹកនាំ និងសម្រេចកិច្ចការរបស់ គណៈកម្មាធិការស្រុកគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងនាមជាប្រធាន និងក្នុងក្របខ័ណ្ឌជាអភិបាលស្រុក ដែលបំពេញមុខងារជាប្រក្រតី រួមទាំងការចុះហត្ថលេខា លើការណែនាំ បទបញ្ជាទាក់ទងនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ ដឹកនាំការប្រជុំរបស់ គណៈកម្មាធិការស្រុកគ្រប់គ្រងគ្រោះមហន្តរាយ និង ដឹកនាំការអនុវត្តន៏គម្រោងសហប្រតិបត្តិការលើវិស័យគ្រប់គ្រងគ្រោះមហន្តរាយ ជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អង្គការអន្តរជាតិ និងដៃគូនានាដែលអនុវត្តន៏នៅក្នុងស្រុករបស់ខ្លួន ហើយ ដឹកនាំការងារប្រចាំថ្ងៃរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក និង :

១. អនុវត្តគោលការណ៍ ដែលទាក់ទងទៅនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ

២. ទំនាក់ទំនង និងផ្តល់ព័ត៌មានទាន់ពេលវេលា ជូន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត

៣. ត្រៀមបង្ការទប់ទល់គ្រប់កាលៈទេសៈ

៤. សហប្រតិបត្តិការ នៅពេលកើតមានគ្រោះមហន្តរាយ

៥. ជួយសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ

៦. ធ្វើផែនការ កម្មវិធីជំនាញ លើកគម្រោងស្នើសុំជាថវិកា សម្ភារ មធ្យោបាយ និងធ្វើរបាយការណ៏ជូនទៅ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត

៧. ដឹកនាំដោយផ្ទាល់កិច្ចប្រតិបត្តិការក្នុងពេលមានគ្រោះមហន្តរាយ រួមមាន ជំនួយសង្គ្រោះ ការជម្លៀស ការផ្តល់ទីជំរក និងការផ្តល់ជំនួយសុខាភិបាល

៨. ទំនាក់ទំនង និងអំពាវនាវដល់កាកបាទក្រហមកម្ពុជា អង្គការមនុស្សធម៌ ជាតិ អន្តរជាតិ សមាគមនានា ដើម្បីចូលរួមជួយសហការឧបត្ថម្ភដល់ការងារគ្រប់គ្រងគ្រោះមហន្តរាយ ។

## ៤.៣ រចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក



## ៤.៤ ក្រុមប្រតិបត្តិការ

| ក្រុមស្រាវជ្រាវរុករកសង្គ្រោះ និងការពារសន្តិសុខ | |
|---|---|
| ■ **សមាសភាពអនុប្រធាន**<br>១. អធិការដ្ឋាននគរបាលស្រុក (អនុប្រធាន)<br>២. បញ្ជាការផ្នែកសឹករងស្រុក (អនុប្រធាន)<br>៣. បញ្ជាការកងអាវុធហត្ថស្រុក (អនុប្រធាន)<br>■ **សមាសភាពសមាជិក :**<br>៤. ប្រធានការិ.អភិវឌ្ឍន៍ជនបទ<br>៥. ប្រធានការិ.ភូមិបាលស្រុក<br>៦. ប្រធានស្រុកប្រតិបត្តិប្រចាំស្រុកកៀនស្វាយ<br>៧. ប្រធានការិយាល័យ កិច្ចការនារីស្រុក<br>៨. ប្រធានការិយាល័យកសិកម្ម<br>៩. ការិយាល័យសាធារណការស្រុក<br>១០. អង្គការនានានៅក្នុងស្រុក | ■ **តួនាទី និង ការទទួលខុសត្រូវ**<br>១. តាមដានព័ត៌មាន និង របាយការណ៍ពីស្ថានភាពនិងផលប៉ះពាល់ ដើម្បីត្រៀមលក្ខណៈ និង ប្រតិបត្តិការសង្គ្រោះ។<br>២. ជួយសង្គ្រោះប្រជាជនដែលងាយរងគ្រោះ និង ប្រជាជនរងគ្រោះ ដោយសារគ្រោះមហន្តរាយទឹកជំនន់ ។<br>៣. កំណត់ប្រជាជនដែលស្ថិតនៅតំបន់ប្រឈមមុខនិងតំបន់ងាយរងគ្រោះ។<br>៤. ជួយអាជ្ញាធរភូមិ ឃុំ និង ក្រុមប្រតិបត្តិការដទៃទៀតទៅតាម ការស្នើសុំជាក់ស្តែង។<br>៥. សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់នៅទីសុវត្ថិភាពដែលជនរងគ្រោះស្នាក់នៅ និងការពារ ទ្រព្យសម្បត្តិ ផ្ទះសំបែងរបស់ប្រជាជនដែលបានភៀសខ្លួន។<br>៦. សហការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីគ្រប់គ្រង និង សង់ជម្រក បណ្តោះអាសន្ននៅទីទួលសុវត្ថិភាព។<br>៧. ផ្តល់ព័ត៌មានពាក់ព័ន្ធដល់អាជ្ញាធរភូមិ ឃុំ និង ចែករំលែកព័ត៌មាន ពាក់ព័ន្ធជាប្រចាំដល់ក្រុមដទៃ ការិយាល័យ និង អង្គភាព និង អង្គការនានានៅក្នុងស្រុក។<br>៨. សហការ និង ជួយសម្របសម្រួលដល់អាជ្ញាធរភូមិ ឃុំ អង្គការនានា ពាក់ព័ន្ធក្នុងការជម្លៀស និងសង្គ្រោះ។<br>៩. ជួយសម្របសម្រួល និង ការពារមធ្យោបាយដឹកជញ្ជូនសម្ភារជំនួយ និង ជួយដឹកប្រជាពលរដ្ឋរងគ្រោះ។<br>១០. ធ្វើការជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីកំណត់មធ្យោបាយ និង ឧបករណ៍សម្រាប់បម្រើឱ្យការងារជម្លៀស និង សង្គ្រោះ។<br>១១. ចូលរួមប្រជុំដើម្បីចែករំលែកព័ត៌មាន បទពិសោធន៍ និងចូលរួមការប្រជុំផ្សេងទៀតតាមការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក។<br>១២. តួនាទីផ្សេងទៀតនឹងអនុវត្តតាមផែនការ និងការចង្អុលបង្ហាញរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក។ |

| ក្រុមសុខភាព អនាម័យ និងទឹកស្អាត | |
|---|---|
